ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៧៨៤ ឧវបន.កសខ.សស.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដំណើរការសេវាកម្មចុះបញ្ជីអនឡាញ សម្រាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សូមជម្រាបជូនសាធារណជន ជ្រាបថា៖ ក្រសួងបានដាក់ឱ្យដំណើរការជាផ្លូវការសេវាកម្មចុះបញ្ជីអនឡាញសម្រាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចាប់ពីថ្ងៃ១៤ ខែមករា ឆ្នាំ២០២៥។

ការដាក់ឱ្យដំណើរការសេវាកម្មចុះបញ្ជីអនឡាញនេះ គឺជាវឌ្ឍនភាពដ៏សំខាន់មួយនៃការអនុវត្តការធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មកម្មសិទ្ធិបញ្ញានៅកម្ពុជា ដែលក្រសួង ឧ.វ.ប.ន សហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្រោមការឧបត្ថម្ភគាំទ្រពីអង្គភាពប្រកាសនីយបត្រតក្កកម្មប្រទេសជប៉ុន(JPO)។ ព្រឹត្តិការណ៍នេះមានគោលបំណងផ្សព្វផ្សាយជូនដល់សាធារណជន និងអ្នកពាក់ព័ន្ធក្នុងវិស័យកម្មសិទ្ធិបញ្ញា អាចចូលមកប្រើប្រាស់សេវាកម្ម ស្នើសុំចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម និងអាចបង់កម្រៃសេវាតាមប្រព័ន្ធអនឡាញ ដោយចូលទៅកាន់៖

https://dip.misti.gov.kh សម្រាប់ស្វែងរកឯកសារបទដ្ឋានគតិយុត្តិ

https://dip.misti.kh.wipo.net សម្រាប់ស្វែងរកមូលដ្ឋានទិន្នន័យប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

https://dip.misti.gov.kh/efiling សម្រាប់ការដាក់ស្នើពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម និងការបង់កម្រៃសេវាតាមប្រព័ន្ធអនឡាញ។ រាល់ចំងល់ដែលទាក់ទងការប្រើប្រាស់វេបសាយខាងលើ អ្នកដាក់សំណុំលិខិតស្នើសុំចុះបញ្ជី អាចទំនាក់ទំនងមកលេខទូរសព្ទ ០៨៨ ២២២ ២២៤៩/ ០១២ ៩៨២ ៣៨២។

ប្រព័ន្ធអនឡាញនេះរួមមានសេវាចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្មដូចជា៖

១. ការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

២. ការដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម

៣. ការស្នើសុំផ្លាស់ប្តូរឈ្មោះ អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឬភ្នាក់ងារតំណាង, ការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ ការស្នើសុំការកែប្រែផ្សេងៗ និងការផ្តល់ឯកសារបន្ថែម

៤. ការចុះបញ្ជីគំនូរឧស្សាហកម្ម និងការបង់កម្រៃសេវានៃការចុះបញ្ជីឡើងវិញ(Renew-Industrial Design)

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៥